ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ៨៧

ចុះថ្ងៃទី០៤ - ១២ - ២០០១

សាលដីកា

លេខ : ៤១

ចុះថ្ងៃទី២៦ - ០៦ - ២០០២

តាងនាមប្រជារាស្ត្រខ្មែរ

# តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី២៦ ខែ មិថុនា ឆ្នាំ ២០០២ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :

១ - ឯកឧត្តម ឃឹម ប៉ុណ្ណ ប្រធាន

២ - លោក ឈឹម ស៊ីផល ចៅក្រម

៣ - លោក ប្រាក់ គឹមសាន ចៅក្រមរបាយការណ៍

៤ - លោក ទៀល ឌួន ចៅក្រម

៥ - លោក ម៉ន សាវឿន ចៅក្រម

លោក ឃាង ស្រ៊ុន ក្រឡាបញ្ជី

តំណាងមហាអយ្យការ

ឯកឧត្តម ជួន ស៊ុនឡេង អគ្គព្រះរាជអាជ្ញាស្តីទី

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខលេខ ៥០ស្ទួន ចុះថ្ងៃទី១៨ - ៥ - ២០០០ របស់ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដែលតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ៨៤ ចុះថ្ងៃទី២៩ ៣ ២០០០ របស់សាលាឧទ្ធរណ៍ ដែលសំរេចលើកយកក្រឹត្យច្បាប់លេខ០២ ចុះថ្ងៃទី១៥ ខែឧសភាឆ្នាំ១៩៨០ ដែលនិរាករណ៍ទុកហើយ មកអនុវត្ត និងសំណុំរឿងព្រហ្មទណ្ឌលេខ ៨៧ ចុះថ្ងៃទី ០៤ - ១២ - ២០០១ របស់ តុលាការកំពូល ។

- ជនជាប់ចោទឈ្មោះគឹម ចាន់ដេត ភេទ ស្រី អាយុ ៤០ ឆ្នាំ ជាតិខ្មែរ កើតនៅភូមិបឹងកុក ឃុំ អោង ស្រុក កំពង់សៀម ខេត្ត កំពង់ចាម កំរិតវប្បធម៌ថ្នាក់ទី៧ចាស់ សាសនា ព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិ៣ ឃុំ ស្មាច់មានជ័យ ខេត្ត កោះកុង មុខរបរលក់ដូរ ។ ឪពុកឈ្មោះហាទ តុង "ស" ម្តាយឈ្មោះ អេង យុន "ស" ប្តីគ្មាន ។

- ជនជាប់ចោទឈ្មោះភូមិ ស៊ីឃី ភេទស្រី អាយុ ៥១ ឆ្នាំ កើតនៅភូមិ កូនសាត់ ស្រុកនិងខេត្ត កំពត កំរិតវប្បធម៌ថ្នាក់ទី៧ចាស់ សាសនាព្រះពុទ្ធ ទីលំនៅភូមិ៣ ឃុំ ដងទង់ ស្រុក ស្មាច់មានជ័យ ខេត្តកោះកុង ប្តីឈ្មោះវ៉ាន់ ឃាង "ស" មានកូន២នាក់ ឪពុកឈ្មោះ ហុង សួន "ស" ម្តាយឈ្មោះ តាន់ ឡាក់ "រ" ។

- ជនជាប់ចោទឈ្មោះលី គីមលីន ហៅហ៊ុយ ភេទប្រុស អាយុ៣០ ឆ្នាំ ជាតិខ្មែរ កើតនៅភូមិគម្លីង ឃុំបំបូរមាស ស្រុកទីរួមខេត្ត កំពង់ចាម សព្វថ្ងៃនៅភូមិទី៣ ឃុំ ដងទង់ ស្រុក ស្មាច់មានជ័យ ខេត្ត កោះកុង ប្រពន្ធឈ្មោះស្លួ គីមឃាង មានកូន០១នាក់ ឪពុកឈ្មោះ ទៀង ឡៀងរ៉ែ ម្តាយឈ្មោះ តាំង ហ៊េង ។

- ត្រូវចោទពីបទៈ ទំលោភលើលំនៅដ្ឋាននិងបំពានបំពានទ្រព្យសម្បត្តិប្រជាជន .

- អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ប្តឹងសាទុក្ខ

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះសាំង សំអុល ភេទប្រុស អាយុ ៣៧ ឆ្នាំ ជាតិ ខ្មែរ មុខរបររកស៊ីអាជីវកម្មម៉ាស៊ីនភ្លើងនិងការរ៉េម សព្វថ្ងៃនៅភូមិ១ ក្រុម៣ សង្កាត់ទី២ ស្រុកទីរួម ខេត្ត កោះកុង ។ ជាចុងបណ្តឹងសាទុក្ខ ។

- តាមពាក្យបណ្តឹងចុះថ្ងៃទី២៤ - ៨ - ៩៤ របស់ឈ្មោះសាំង សំអុល ប្តឹងពីឈ្មោះ គីម ចាន់ដេត ភូ ស៊ីម៉ី និងលី គីមលីន ហៅហ៊ុយ ថាបានចូលទៅរើរុះឥវ៉ាន់ ក្នុងលំនៅដ្ឋានរបស់ខ្លួន ដើម្បីទូទាត់ប្រាក់បំណុល កាលពីថ្ងៃទី២០ - ៦ - ១៩៩៤ ដ៏នៅឱកាសពេលប្តីប្រពន្ធខ្លួនមិននៅផ្ទះ ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមតុលាការខេត្តកោះកុងសំរេច: ចោទប្រកាន់លើ១ - ឈ្មោះ គីម ចាន់ដេត ភេទប្រុស អាយុ ៤០ ឆ្នាំ ២ - ឈ្មោះលី គីមលីន ភេទ ប្រុស អាយុ ៣០ ឆ្នាំ ៣ - ឈ្មោះ ភូ ស៊ីម៉ី ភេទស្រី អាយុ ៥១ ឆ្នាំ ពីបទ: បំពារបំពានលើទ្រព្យសម្បត្តិរបស់ប្រជារាស្ត្រ ប្រព្រឹត្តនៅភូមិ១ ឃុំដងទង់ ស្រុកស្មាច់មានជ័យ ខេត្តកោះកុង កាលពីថ្ងៃទី២០ - ៦ - ១៩៩៤ ។បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមប្រការ៨ នៃ ក្រឹត្យច្បាប់លេខ ០២ ក្រ.ច ចុះថ្ងៃទី ១៥ - ៥ - ១៩៨០ ។

- បានឃើញសាលក្រមលេខ ៣៣ ចុះថ្ងៃទី ២៤ - ១០ - ១៩៩៧ របស់តុលាការ ខេត្តកោះកុង ដែលមានខ្លឹមសារដូចតទៅ :

១ - ផ្តន្ទាទោសឈ្មោះនារី គីម ចាន់ដេត នារី ភូ ស៊ីម៉ី និងឈ្មោះលីគីម លីន ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់១ឆ្នាំ តែទោសនេះត្រូវព្យួរទុកពេលសាកល្បង៥ ឆ្នាំ គិតពីថ្ងៃ សាលក្រមចូលជាស្ថាពរ ពីបទ ទំលោភលំនៅដ្ឋាននិងបំពារបំពានទ្រព្យសម្បត្តិផ្ទាល់របស់ប្រជាជន ប្រព្រឹត្តនៅភូមិ០១ ឃុំដងទង់ ស្រុកស្មាច់មានជ័យ ខេត្តកោះកុង កាលពីថ្ងៃទី២០ - ០៦ - ១៩៩៤។ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមប្រការ៨នៃក្រឹត្យច្បាប់លេខ០២ក្រ.ច ចុះថ្ងៃទី១៥ - ០៥ - ១៩៨០ និងមាត្រា៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២ - វត្ថុតាង :

- ម៉ាស៊ីនភ្លើងសូវៀតផ្ទះ ០១ គ្រឿង ចានស្រាក់០១គ្រឿង បំពង់ទឹក ក្តៅ០១ ពាងដាក់ទឹក០១ ទ្រូគ្រប់អប់០១, ម៉ាស៊ីនភ្លើងម៉ីស៊ូប៊ីស៊ី០១គ្រឿង គម្របកញ្ចក់ចំនួន៣ តាបឡូម៉ាស៊ីនភ្លើង០១, ដេម៉ារទ័រ២៤វ៉ុល០១ ស្លាបកង្ហារម៉ូតា០១ ស្លាបកង្ហារម៉ាស៊ីនទឹកកក០១, ម៉ូទ័រម៉ាស៊ីនភ្លើង០១ ពាងដាក់ទឹក០៣ គ្រឿងរខ្វាស់សំរាប់ម៉ាស៊ីនភ្លើង០១ ឱ្យរកាត់មាត់ ត្រូវប្រគល់អោយម្ចាស់ដើមវិញ ។ ទ្រព្យសម្បត្តិទាំងអស់នេះ បានប្រគល់តាំងពីថ្ងៃទី២៨ .០២ ១៩៩៥ ។

....៣ ...

៣-សំណង :

- អោយឈ្មោះលី គីមលីន នារីភូ ស៊ុយី និងឈ្មោះគីម ចាន់ដេត រួមគ្នាសង ការបាត់បង់ទ្រព្យសម្បត្តិ គិតជាប្រាក់ចំនួន៥៧.៥២៩បាត ទៅឈ្មោះសាំង សំអុល ។

៤-សាលក្រមនេះ ជំនុំជំរះជាសាធារណៈ ចំពោះមុខដើមបណ្តឹងនារីជន ជាប់ចោទភូ ស៊ុយី នារី គីមចាន់ដេត និងកំបាំងមុខជនជាប់ចោទឈ្មោះលី គីមលីន បើកផ្លូវប្តឹង ទាស់រយៈពេល១៥ថ្ងៃ និងប្តឹងឧទ្ធរណ៍រយៈពេល២ខែ គិតចាប់ពីថ្ងៃផុតកំណត់ប្តឹងទាស់ ។

- បានឃើញបណ្តឹងឧទ្ធរណ៍លេខ ០៤ ចុះថ្ងៃទី២៨-១០-១៩៩៧ របស់ឈ្មោះ សាំង សំអុល តវ៉ាពីសាលក្រមលេខ៣៣ ចុះថ្ងៃទី២៤-១០-១៩៩៧ របស់តុលាការខេត្តកោះកុង លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា :

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២៨-១០-១៩៩៧ របស់ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះសាំង សំអុល ទុកជាត្រឹមត្រូវតាមទំរង់និងគតិច្បាប់ ។

២-រក្សាសាលក្រមលេខ ៣៣ ចុះថ្ងៃទី២៤-១០-១៩៩៧ របស់តុលាការ ខេត្ត កោះកុងតាមការយល់ឃើញខាងលើ ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ៨៤ ចុះថ្ងៃទី២៩-៣-២០០០ របស់ សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារសេចក្តីសំរេចដូចតទៅ :

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ ១៩៩៧ របស់ដើមបណ្តឹងឈ្មោះ សាំង សំអុល ទុកជាត្រឹមត្រូវតាមទំរង់ តែបដិសេធចោលដោយទាស់និងគតិច្បាប់ ។

២-តំកល់សាលក្រមលេខ ៣៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ ១៩៩៧ របស់តុលាការ ខេត្ត កោះកុង ទុកជាបានការទាំងមូល ។

៣-សាលដីកានេះជំនុំជំរះនិងប្រកាសជាសាធារណៈ កំបាំងមុខជនជាប់ចោទ ឈ្មោះភូ ស៊ុយី លី គីមលីន និងដើមបណ្តឹងរដ្ឋប្បវេណីនិងចំពោះមុខជនជាប់ចោទឈ្មោះគីម ចាន់ដេត បើកផ្លូវប្តឹងជំទាស់និងសាទុក្ខ ក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្តឹងសាទុក្ខលេខ ៥០ស្ទួន ចុះថ្ងៃទី១៨-០៥-២០០០ របស់ អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ តវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ៨៤ចុះថ្ងៃទី២៩-៣-២០០០របស់ សាលាឧទ្ធរណ៍ ត្រង់ចំណុចដែលសំរេចលើកយកក្រឹត្យច្បាប់លេខ០២ចុះថ្ងៃទី០៥-០៥-១៩៨០ដែល និរាករណ៍ផុតហើយ យកមកអនុវត្ត ។

- បានឃើញសារណាចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ ២០០១ របស់ អគ្គព្រះរាជ អាជ្ញាសាលាឧទ្ធរណ៍ ។

- បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : មានភស្តុតាង បញ្ជាក់ថា :ពួកជនជាប់ចោទ បានប្រគល់ទ្រព្យដែលលួចនោះ ឱ្យម្ចាស់វិញហើយ ប៉ុន្តែនៅ

មានមួយចំនួនទៀត ។ អំពើល្មើសដែលកើតឡើងសុទ្ធតែដើមបណ្តឹងអ្នកឱ្យហេតុមុន ពីព្រោះជំពាក់លុយជនល្មើសមិនបានសង គួរតែឲ្យតុលាការពិចារណាអំពីស្ថានសំរាលទោស និងសូមបដិសេធសាលដីកាសាលាឧទ្ធរណ៍ចោលជាអសារបង់ ។

- បានស្តាប់សារណាបណ្តឹងសាទុក្ខចុះថ្ងៃទី០៣ - ០៨ - ២០០១ របស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ .

- បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការថា៖ ពុំមានអ្វីបន្ថែមទៀតទេ សូមរក្សាការសន្និដ្ឋានរបស់ខ្លួនទៅដដែល ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ .

- ក្រោយពីបានស្តាប់សារណារបស់ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍.

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ .

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ៥០ស្ទួន ចុះថ្ងៃទី១៨-៥-២០០០ របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូល អាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ក៏ដូចតុលាការខេត្តកោះកុងដែរ ដែលលើកយកប្រការ៨ នៃក្រឹត្យច្បាប់លេខ០២ ក្រ.ច ចុះថ្ងៃទី១៥ - ៥ - ៨០ មកផ្តន្ទាទោសឈ្មោះគីម ចាន់ដេត ឈ្មោះភូ ស៊ីឃី និងឈ្មោះលី គឹមលីន ពីបទរំលោភលំនៅដ្ឋាននិងបំពារបំពានទ្រព្យសម្បត្តិអ្នកដទៃប្រព្រឹត្តនៅភូមិ១ ឃុំដងទង់ ស្រុកស្មាច់មានជ័យ ខេត្ត កោះកុង កាលពីថ្ងៃទី២០ - ៦ - ៩៤ នោះ គឺជាការភន្តច្រឡំ ពីព្រោះប្រការ៨នៃក្រឹត្យច្បាប់លេខ០២ ក្រ.ច ចុះថ្ងៃទី១៥ - ៥ - ៨០ ត្រូវនិរាករណ៍ តាមមាត្រា៤៣ និង៥៧ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលហើយ ។

- យល់ឃើញថា ថ្វីបើតុលាការខេត្ត កោះកុងនិងសាលាឧទ្ធរណ៍សំរេចអំពីបទចោទខុសក្តីពិត ប៉ុន្តែការកំណត់ទោសរបស់តុលាការទាំងពីរត្រឹមត្រូវតាមការកំណត់ នៃមាត្រា ៤៣ និង ៥៧ នៃ ច្បាប់ព្រហ្មទណ្ឌអន្តរកាលហើយ ដូច្នេះដើម្បីអនុវត្តឲ្យស្របនឹងច្បាប់គប្បីតុលាការកំពូលតម្កល់សាលដីកាលេខ ៨៤ ចុះថ្ងៃទី ២៩ - ៣ - ២០០០ របស់សាលាឧទ្ធរណ៍ទុកជាបានការ ដោយកែប្រែបទចោទអោយបានត្រឹមត្រូវតាមច្បាប់ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យ សេចក្តី

១ - ទទួលបណ្តឹងសាទុក្ខលេខ ៥០ ស្ទួន ចុះថ្ងៃទី ១៨ - ៥ - ២០០០ របស់

.....៥ ....

ឯកឧត្តម អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២ - តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៨៤ ចុះថ្ងៃទី ២៩ - ៣ - ២០០០ របស់សាលាឧទ្ធរណ៍ ចាត់ទុកជាបានការ ដោយកែប្រែចំណុចទី១ នៃសាលក្រមព្រហ្មទណ្ឌលេខ ៣៣ ចុះថ្ងៃទី២៤-១០-៩៧ របស់ តុលាការខេត្ត កោះកុងទោះជា :

- ផ្តន្ទាទោសនារី គីម ចាន់ដេត នារី ភូ ស៊ីហ៊ី និងឈី គីមលើន ដាក់ពន្ធនាគារ ក្នុងម្នាក់ៗកំណត់១ ឆ្នាំ ប៉ុន្តែទោសនេះត្រូវព្យួររយៈពេលសាកល្បង ៥ ឆ្នាំ គិតពីថ្ងៃសាលក្រមចូលជាស្ថាពរ ពីបទរំលោភលំនៅដ្ឋាននិងលួចទ្រព្យសម្បត្តិប្រជាជនប្រព្រឹត្តនៅភូមិ១ ឃុំដងទុង ស្រុកស្មាច់មានជ័យ ខេត្ត កោះកុង កាលពីថ្ងៃទី២០ - ៦ - ១៩៩៤ ។

បទល្មើសដែលមានចែងនិងផ្តន្ទាទោសតាមមាត្រា ៤៣ និង ៥៧នៃច្បាប់ព្រហ្មទណ្ឌ អន្តរកាល ។

៣ - សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០២ ។